ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០២៦៥ ព.ណ..គ.ពា..

ថ្ងៃ ពុធ ១កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឲ្យបានជ្រាបថា៖ ក្រុមប្រឹក្សាជំរុញការនាំចេញផ្នែកឧបករណ៍ និងសេវាកម្មទូរគមនាគមន៍ (TEPC) ដែលស្ថិតនៅក្រោមគម្រោងផ្តួចផ្តើមចូលទីផ្សាររបស់នាយកដ្ឋានពាណិជ្ជកម្មនៃរដ្ឋាភិបាលឥណ្ឌា នឹងរៀបចំពិធីតាំងពិព័រណ៍ **"Telecom 2022-An Exclusive International Business Expo"** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៨-១០ ខែកុម្ភៈ ឆ្នាំ២០២២ ខាងមុខ តាមប្រព័ន្ធអនឡាញ។

ក្នុងឱកាសនេះ គណៈកម្មការរៀបចំពិព័រណ៍ TEPC សូមអញ្ជើញក្រុមហ៊ុនកម្ពុជាដែលកំពុងធ្វើធុរកិច្ចលើផលិតផលឧបករណ៍ទូរគមនាគមន៍ និងអ្នកផ្គត់ផ្គង់សេវាកម្មអិនធើណេត ហើយមានចំណាប់អារម្មណ៍ចង់នាំចូលផលិតផលឧបករណ៍ទូរគមនាគមន៍ពីប្រទេសឥណ្ឌាចូលមកផ្គត់ផ្គង់ទីផ្សារកម្ពុជា សូមអញ្ជើញចុះឈ្មោះចូលរួមតាមគេហទំព័រ **https://www.india-telecom.in**។

ទន្ទឹមនេះ គណៈកម្មការរៀបចំពិព័រណ៍ TEPC ក៏នឹងមានរៀបចំជំនួបពាណិជ្ជកម្ម (B2B) រវាងក្រុមហ៊ុនឥណ្ឌា និងក្រុមហ៊ុនកម្ពុជាផងដែរ។ ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអ្នកសម្របសម្រួល ជាមួយស្ថានទូតឥណ្ឌាប្រចាំនៅរាជធានីភ្នំពេញ សូមអញ្ជើញលោក លោកស្រីដែលជាពាណិជ្ជករ ម្ចាស់ក្រុមហ៊ុន/សហគ្រាស ព្រមទាំងសាធារណជនទូទៅដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងកម្មវិធីជំនួបពាណិជ្ជកម្មខាងលើ សូមទាក់ទងដោយផ្ទាល់៖
លោក Arun Gupta, DG, Email: dg@telecomepc.in ឬ tepc@telecomepc.in

សម្រាប់ពត៌មានបន្ថែមស្តីពីពិព័រណ៍ **Telecom 2022-An Exclusive International Business Expo** សូមចូលទៅកាន់វេបសាយដែលមានអាសយដ្ឋាន **https://www.india-telecom.in**

សូមអរគុណ

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469